# ព្រឹត្តិបត្រក្រុមប្រឹក្សាអាជ្ញាកណ្តាល

## ព័ត៌មានថ្មីៗអំពីទំនាក់ទំនងវិជ្ជាជីវៈ និងការដោះស្រាយវិវាទការងារនៅកម្ពុជា

ខែតុលា-ធ្នូ ឆ្នាំ២០១០

ដោះស្រាយវិវាទការងាររួម

## មាតិកា


- ការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ១
- កម្មករនិយោជិត និងអ្នកគ្រប់គ្រង ពិភាក្សាអំពីដំណោះស្រាយចំពោះការចរចារអនុសញ្ញារួម ២
- ការប្តេជ្ញាចិត្តដើម្បីបង្កើនសមត្ថភាពរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទការងារ ៤
- តំណាងនិយោជក និងសហជីពស្វែងយល់អំពីអនុស្សារណៈនៃការយោគយល់គ្នានៅក្នុង វិស័យកាត់ដេរ សំលៀកបំពាក់ និងដំណើរការមជ្ឈត្តកម្មការងារ ៤
- ការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នាក្នុងឧស្សាហកម្មកាត់ដេរអាចបង្កើនប្រាក់ចំណេញ និងប្រាក់ឈ្នួល ៥
- លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រៀមទទួលចុះបញ្ជីសំណុំរឿងវិវាទការងារដែលគ្រប់ដណ្តប់ដោយអនុស្សារណៈនៃការយោគយល់គ្នាក្នុងវិស័យកាត់ដេរ ៦


## ការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល

(សំណុំរឿងចាប់ពីខែមករា - ធ្នូ ២០១០)




ក្នុងឆ្នាំ ២០១០ សំណុំរឿងចំនួន ១៤៥ រវាងនិយោជក និងសហជីព កម្មករ បានយកមកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្នុងនោះ សំណុំរឿងចំនួន ៣០ ត្រូវបានដោះស្រាយដែលភាគីបានឈានដល់កិច្ចព្រមព្រៀង ដោយបានជំនួញពីក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ១០៤ សំណុំរឿង ត្រូវបានដោះស្រាយតាមការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលនិង ១១ សំណុំរឿងនៅមិនទាន់បានដោះស្រាយ ហើយសំណុំរឿងនោះនឹងយកទៅដោះស្រាយនៅឆ្នាំ២០១១។

ចាប់តាំងពីពេលបដិសន្ធិនៅឆ្នាំ ២០០៣ មក ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលសំណុំរឿងសរុបចំនួន ៩៧៨ សំណុំរឿង។ ក្រាហ្វិកខាងក្រោម បង្ហាញពីប្រភេទសំណុំរឿងនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមវិស័យនិងភូមិសាស្ត្រ។




*ប្រភេទសំណុំរឿងនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមវិស័យ*

យោងតាមក្រាហ្វិកដែលបានបង្ហាញ ភាគច្រើននៃសំណុំរឿងវិវាទការងារ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលគឺមកពីវិស័យកាត់ដេរ។

នៅក្នុងន័យនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់សេវាដល់វិស័យកាត់ដេរ ដែលជាវិស័យដ៏ចំបងសំរាប់ការនាំចេញរបស់ប្រទេសកម្ពុជាដែលផ្តល់ការងារនិងប្រាក់ចំណូលដល់កម្មករ ៣៥០ ០០០នាក់ ដែលភាគច្រើនជាស្ត្រីដែលមកពីជនបទ។

ដូចដែលក្រាហ្វិកបានបង្ហាញភាគច្រើននៃវិវាទគឺចេញពីតំបន់ក្រុងភ្នំពេញ និងខេត្តកណ្តាល។ វាមានលក្ខណៈស៊ីចង្វាក់ ជាមួយនឹងតំបន់រោងចក្រនិងវិស័យផ្សេងៗតាំងទី។




*ប្រភេទសំណុំរឿងនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមភូមិសាស្ត្រ*

ជារួម យើងឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានជួយដោះស្រាយវិវាទរវាងនិយោជក និងសហជីព កម្មករ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្តល់ជាជំនួញក្នុងការដោះស្រាយវិវាទដែលជារនាំង និងភាពរំខានដល់សកម្មភាពដ៏ចំបងរបស់សហគ្រាសក៏ដូចជា កម្មករ ដែលអាចជួយរក្សានិងលើកកំពស់ប្រាក់ចំណេញ/ផលិតភាព។

# កម្មករនិយោជិត និងអ្នកគ្រប់គ្រង ពិភាក្សាអំពីដំណោះស្រាយចំពោះការចរចារអនុសញ្ញារួម




*លោក សុខ ឡោ នាយកប្រតិបត្តិមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល, ឯកឧត្តម សេង សក្កា អគ្គនាយកនៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, លោក ម៉ៃ យើលហ្គេ អាជ្ញាកណ្តាលនៃស្ថាប័នការងារយុត្តិធម៌នៃប្រទេសអូស្ត្រាលី ថ្លែងសុន្ទរកថានៅសន្និសីទថ្នាក់ជាតិលើកទី៥ ស្តីពីទំនាក់ទំនងវិជ្ជាជីវៈ*

ភ្នំពេញថ្ងៃទី០១ ខែ តុលា ឆ្នាំ២០១០ តំណាងសហជីពកម្មករនិយោជិត និយោជក រដ្ឋាភិបាល និងសង្គមស៊ីវិល បានជួបជុំគ្នា ដើម្បីចែករំលែកបទពិសោធន៍ជាក់ស្តែង និងពិភាក្សាអំពីដំណោះស្រាយរួម លើបញ្ហាប្រឈមនាពេលបច្ចុប្បន្នដែលបង្កអោយមានការលំបាកដល់ស្ថេរភាពឧស្សាហកម្មនិងដំណើរឆ្ពោះទៅមុខនៃការចរចារអនុសញ្ញារួម។

បញ្ហាប្រឈមចំបងរួមមានការប្រកួតប្រជែងរវាងសហជីពនៅក្នុងសហគ្រាសនីមួយៗដែលក្នុងនោះ សហជីពតូចៗមិនមានឆន្ទៈក្នុងការធ្វើសហប្រតិបត្តិការជាមួយសហជីព ដែលមានភាពជាតំណាងបំផុត ក្នុងការចរចារអនុសញ្ញារួម និងការខ្វះជំនាញរបស់ភាគី ព្រមទាំងការមិនយល់ពីអត្ថប្រយោជន៍ពិតប្រាកដរបស់អនុសញ្ញារួម។ នេះបើផ្អែកតាមមតិអ្នកចូលរួមក្នុងសន្និសីទថ្នាក់ជាតិស្តីពីទំនាក់ទំនងលើកទី៥ ដែលរៀបចំដោយមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅសណ្ឋាគារ Raffles Hotel Le Royal។

អ្នកចូលរួមជាច្រើនបានស្វាគមន៍កិច្ចព្រមព្រៀងដែលសំរេចបាន កាលពីដើមសប្តាហ៍ រវាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងប្រធានសហពន្ធ័សហជីពធំៗស្តីពីការដោះស្រាយវិវាទការងារ ដោយនិយាយថា នេះឆ្លុះបញ្ចាំងពីការយល់កាន់តែច្រើនឡើងពីសារសំខាន់នៃអនុសញ្ញារួម។

លោក សុខ ឡោ នាយកប្រតិបត្តិមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលមានប្រសាសន៍ថាគោលបំណងសំខាន់នៃសន្និសីទនេះគឺផ្តោតលើ "គន្លឹះយូរអង្វែងឆ្ពោះទៅរកស្ថេរភាពក្នុងវិស័យទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការពិនិត្យឡើងវិញអំពីការចរចារអនុសញ្ញារួម និងគំនិតផ្តួចផ្តើមអំពី ការធ្វើអាជ្ញាកណ្តាលចងកាតព្វកិច្ច ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល"។

លោក សុខ ឡោ មានប្រសាសន៍ថា "ការចរចារអនុសញ្ញារួមមានសារៈសំខាន់យ៉ាងចាំបាច់ក្នុងទំនាក់ទំនងវិជ្ជាជីវៈ"។

លោកបានបន្ថែមដែរថា ការចរចារអនុសញ្ញារួម លើកកំពស់ផលិតភាព និងកំណើនសេដ្ឋកិច្ចដែលនឹងចូលរួមចំណែក ក្នុងការធានាសន្តិភាពសង្គមផងដែរ។

ឯកឧត្តម សេង សក្កា អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការចរចារអនុសញ្ញារួមក្នុងការធានាទំនាក់ទំនងការងារដែលមានស្ថេរភាពផងដែរ។

ឯកឧត្តម មានប្រសាសន៍ថា "អនុសញ្ញារួមដែលប្រកបដោយប្រសិទ្ធិភាព នឹងទាក់ទាញវិនិយោគទុនបរទេស មិនត្រឹមតែវិស័យកាត់ដេរ និងវាយនភ័ណ្ឌប៉ុណ្ណោះទេ គឺថែមទាំងវិស័យសណ្ឋាគារទេសចរណ៍ និងសំណង់ថែមទៀតផង"។

លោកអាជ្ញាកណ្តាល ម៉ៃយើល ហ្គេ នៃស្ថាប័នការងារយុត្តិធម៌នៃប្រទេសអូស្ត្រាលី បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការកែប្រែថ្មីៗនៅប្រទេសអូស្ត្រាលីដែលបានដាក់បញ្ចូលនូវកាតព្វកិច្ចតាមច្បាប់ក្នុងការចរចារដោយភាពស្មោះត្រង់។

"ខ្ញុំជឿថាអ្វីដែលអ្នកទាំងអស់គ្នាអាចនឹងចាប់អារម្មណ៍គឺកាតព្វកិច្ចតាមច្បាប់ ក្នុងការចរចារដោយភាពស្មោះត្រង់ និងកាតព្វកិច្ចក្នុងការធ្វើឲ្យគេឃើញថាអ្នកកំពុងតែចរចារដោយភាពស្មោះត្រង់ នៅក្នុង

*តទៅទំព័រ ៣*



*អ្នកចូលរួមនៅសន្និសីទថ្នាក់ជាតិលើកទី ៥ ស្តីពីទំនាក់ទំនងវិជ្ជាជីវៈ*

**កម្មករនិយោជិត...**

*តមកពីទំព័រ ២*




*លោក ចន រីឆេត់ អ្នកជំនាញផ្នែក ទំនាក់ទំនងវិជ្ជាជីវៈរបស់អង្គការពលកម្មអន្តរជាតិ*

ដំណាក់កាលនៃការចរចារអនុសញ្ញារួម"។

នេះបើតាមប្រសាសន៍អាជ្ញាកណ្តាល ម៉ៃយើល ហ្គេ ដែលបានធ្វើការដោះស្រាយវិវាទទាក់ទងនឹងកូដកម្មនៅតាមបណ្តាសណ្ឋាគារធំៗមួយចំនួននៅទីក្រុងភ្នំពេញ និងខេត្តសៀមរាបកាលពីឆ្នាំ២០០៤។

លោកក៏បានសង្កត់ធ្ងន់ផងដែរលើការដែលថា អនុសញ្ញារួមត្រូវតែមានប្រសិទ្ធភាព និងស្ថិតស្ថេរ។

លោកបន្ថែមថា "អនុសញ្ញារួម ត្រូវតែមានភាពលំអិត និងមិនជ្រាបទឹកដើម្បីនាំមកនូវភាពសុខសាន្តនៅរោងចក្រ"។ លោកក៏បានប្រៀបធៀបទៅប្រទេសអូស្ត្រាលី ដែលអនុសញ្ញារួមសព្វថ្ងៃឈានដល់ការចែងអំពី "កាយវិការដែលអាចទទួលយកបាន"និងចែងយ៉ាងច្បាស់អំពីនីតិវិធីដោះស្រាយវិវាទ។

លោក ចន រីឆេត់ ដែលជាអ្នកជំនាញផ្នែកទំនាក់ទំនងវិជ្ជាជីវៈរបស់អង្គការពលកម្មអន្តរជាតិបានកោតសរសើរចំពោះការវិវឌ្ឍន៍នៃទំនាក់ទំនងវិជ្ជាជីវៈ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះនៅប្រទេសកម្ពុជា។ ប៉ុន្តែលោកមានប្រសាសន៍ថា កិច្ចសន្ទនារវាងភាគីទាំងសងខាងដែលកាន់តែប្រសើរឡើង និងការយោគយល់គ្នាថែមទៀតអំពីផលប្រយោជន៍របស់គ្នាទៅវិញទៅមកនឹងនាំឱ្យមានអនុសញ្ញារួមមួយដ៏ល្អប្រសើរ។

លោកបន្ថែមថា "ការចរចាររួមមិនមែនជាផ្លូវឯកទិសទេ" តែគួរតែផ្តល់ប្រយោជន៍ដល់ទាំងកម្មករ និងថៅកែ។

លោក ចន និង ម៉ៃយើល លើកទឹកចិត្តឲ្យមានខចែងស្តង់ដារមួយចំនួនក្នុងអនុសញ្ញារួម ដូចជាការធ្វើអាជ្ញាកណ្តាលចងកាតព្វកិច្ចដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ការមិនធ្វើវិធានការឧស្សាហកម្ម និងការដាក់កំហិតមិនឲ្យធ្វើការទាមទារបន្ថែមក្នុងកំឡុងពេលមានអនុសញ្ញារួម ។

លោក អាត់ ធន់ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា លោក សោម អូន ប្រធានសហពន្ធ័សហជីពកម្មករកម្ពុជា និង លោក ឈិន សូនី អនុប្រធានសហពន្ធ័សហជីពការងារកម្មករកម្ពុជា យល់ថាសហជីពទាំងអស់គួរតែចរចារអនុសញ្ញារួម ដោយសម្លេងតែមួយរួមគ្នាដើម្បីការវិវឌ្ឍន៍ទៅមុខនៃអនុសញ្ញារួម។

លោក សោម ចំណាន នាយកប្រតិបត្តិ និងទីប្រឹក្សាច្បាប់នៃ សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជាបានមានប្រសាសន៍ថា "[អនុសញ្ញារួម] គឺជាឧបករណ៍ដ៏ល្អសម្រាប់រក្សាទំនាក់ទំនងរវាងភាគីទាំងសងខាង"។

លោក លើកទឹកចិត្តឱ្យសមាជិករបស់សមាគមនិយោជករៀបចំខ្លួនចូលរួមក្នុងវគ្គបណ្តុះបណ្តាលទាក់ទងនឹងការចរចារអនុសញ្ញារួមនានា ដើម្បីត្រៀមខ្លួនចរចារអនុសញ្ញារួម នៅពេលដែល "បរិយាកាសអំណោយផល"។

អ្នកចូលរួមយល់ស្របគ្នាថា ការយល់ដឹងបន្ថែមទៀតអំពីផលប្រយោជន៍ និងជំនាញនៃការចរចារអនុសញ្ញារួមនឹងជួយដល់ការវិវឌ្ឍន៍ទៅមុខនៃអនុសញ្ញារួម។ អនុសញ្ញារួមនឹងនាំមកនូវភាពសុខដុមរម្យនានៅសហគ្រាស គ្រឹះស្ថាននៅប្រទេសកម្ពុជា។

**អំពីសន្និសីទជាតិស្តីពីវិជ្ជាជីវៈ**

សន្និសីទជាតិស្តីពីវិជ្ជាជីវៈនៅកម្ពុជារៀបចំដោយមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល។

សន្និសីទនេះជាវេទិកាសម្រាប់អ្នកពាក់ពន្ធ័សំខាន់ៗក្នុងវិស័យការងារ អាចធ្វើការសន្ទនាដើម្បីធ្វើឱ្យទំនាក់ទំនងវិជ្ជាជីវៈកាន់តែប្រសើរឡើង ហើយតាមរយៈនេះ ចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។

សន្និសីទថ្នាក់ជាតិលើកទី៥នេះត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០នៅសណ្ឋាគារ Raffles Hotel Le Royal ក្រោមការឧបត្ថម្ភថវិកាពីគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន របស់ធនាគារពិភពលោក។ ប្រធានបទសម្រាប់ឆ្នាំនេះគឺ ការចរចារអនុសញ្ញារួម ដើម្បីទំនាក់ទំនងវិជ្ជាជីវៈកាន់តែប្រសើរ៖ ដំណោះស្រាយរួមចំពោះបញ្ហាប្រឈមនាពេលបច្ចុប្បន្ន។ ក្រុមពិភាក្សាដែលមានលក្ខណៈឆ្លើយឆ្លងបួនក្រុមផ្តោតលើបញ្ហាប្រឈម ក្នុងការចរចារអនុសញ្ញារួម ផលប្រយោជន៍ចំពោះកម្មករនិយោជិត និយោជក វិនិយោគិន និងសេដ្ឋកិច្ចជាតិ ហើយបន្ទាប់មកលើកអនុសាសន៍អំពីដំណោះស្រាយចំបងនានា ដើម្បីការចរចារអនុសញ្ញារួមនាំមកបានយ៉ាងពិតប្រាកដ នូវភាពសុខដុមរម្យនាក្នុងទំនាក់ទំនងវិជ្ជាជីវៈនៅប្រទេសកម្ពុជា។




*(ពីឆ្វេងមកស្តាំ) លោក អាត់ ធន់ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា, លោក សោម អូន ប្រធានសហពន្ធ័សហជីពកម្មករកម្ពុជា, លោក ម៉ៃ យើលហ្គេ អាជ្ញាកណ្តាល នៃស្ថាប័នការងារយុត្តិធម៌នៃប្រទេសអូស្ត្រាលី, លោក ឈិន សូនី អនុប្រធានសហពន្ធ័សហជីពការងារកម្មករកម្ពុជា និងលោក សោម ចំណាន នាយកប្រតិបត្តិ និងទីប្រឹក្សាច្បាប់នៃ សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា*

# ការប្តេជ្ញាចិត្តដើម្បីបង្កើនសមត្ថភាពរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងការដោះស្រាយវិវាទការងារ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្តេជ្ញាចិត្តបន្តកសាងសមត្ថភាពរបស់ខ្លួនដើម្បីដោះស្រាយវិវាទការងាររបស់និយោជកនិង សហជីព កម្មករ។ ការកសាងសមត្ថភាពរបស់ស្ថាប័នត្រូវធ្វើឡើងតាមរយៈកម្មវិធីមួយចំនួនដែលជួយឲ្យអាជ្ញាកណ្តាល និងបុគ្គលិកមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានបទពិសោធន៍ពីការអនុវត្តល្អបំផុតកម្រិតអន្តរជាតិ។


គណៈប្រតិភូតំណាងក្រុមប្រឹក្សាអាជ្ញាកណ្តាល និងលោក ធីម លី អ្នកគ្រប់គ្រងទូទៅ របស់ស្ថាប័នការងារយុត្តិធម៌ប្រទេសអូស្ត្រាលី

ចាប់ពីថ្ងៃទី ២៩ ខែវិច្ឆិកា ដល់ថ្ងៃទី ១០ខែធ្នូ ឆ្នាំ ២០១០ តំណាង៥រូបរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើបំលាស់ប្តូរដំណើរទស្សនកិច្ចអន្តរជាតិ ទៅ Fair Work Australia (FWA) ប្រទេសអូស្ត្រាលី ដែលជាដៃគូររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដោយមានការចូលរួមចាប់ដៃគូមួយទល់នឹងមួយជាមួយអាជ្ញាកណ្តាល និងបុគ្គលិករបស់ស្ថាប័ន FWA គណៈប្រតិភូបានស្វែងយល់ស៊ីជម្រៅ អំពីប្រព័ន្ធប្រតិបត្តិការទាំងមូល រចនាសម្ព័ន្ធគ្រប់គ្រងសំណុំរឿង និងជំនាញផ្សះផ្សា និងមជ្ឈត្តកម្ម។ គណៈប្រតិភូយល់ឃើញថា ចំណេះដឹង និងបទពិសោធបន្ថែមនេះ មានសារៈប្រយោជន៍ សម្រាប់ការពង្រឹងសមត្ថភាពរបស់ពួកគេ ក្នុងការដោះស្រាយវិវាទការងារ ការគ្រប់គ្រងសំណុំរឿង និងជំនាញទំនាក់ទំនង។

អ្នកនាង ស៊ូ សោភា នាយកផ្នែកច្បាប់នៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បាននិយាយថា ក្នុងអំឡុងពេលកម្មវិធីការផ្លាស់ប្តូរពិសោធន៍ជាអន្តរជាតិនេះ “នាងខ្ញុំបានស្វែងយល់យ៉ាងច្រើនអំពីបច្ចេកទេសផ្សះផ្សាពីអាជ្ញាកណ្តាលផ្សេងៗគ្នារបស់ស្ថាប័ន FWA។ ខ្ញុំកត់សំគាល់ថាឆន្ទៈរបស់ភាគីវិវាទក្នុងការដោះស្រាយវិវាទគឺជាកត្តាគន្លឹះនាំឲ្យមានការផ្សះផ្សាប្រកបដោយជោគជ័យ។ ការជួយដោយភាគីទីបី ដែលហៅថាអ្នកផ្សះផ្សាក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សះផ្សាប្រកបដោយជោគជ័យមួយដែរដោយសារតែអ្នកផ្សះផ្សាអាចជួយបញ្ជាក់ និងជីកកកាយអំពីការបារម្ភណ៍ និងផលប្រយោជន៍របស់ភាគី។ តួនាទីរបស់អ្នកផ្សះផ្សាកាន់តែមានសារៈសំខាន់ជាងនេះទៅទៀតក្នុងស្ថានភាពមួយដែល ភាគីវិវាទទាំងពីរខកខានមិនបានធ្វើការប្រាស្រ័យទាក់ទងដោយផ្ទាល់ ដោយសារតែអ្នកផ្សះផ្សាអាចជួយភ្ជាប់ទំនាក់ទំនងរវាងភាគីវិវាទហើយនៅក្នុងសំណុំរឿងភាគច្រើនអាចជួយភាគីឲ្យចុះកិច្ចព្រមព្រៀងដែលអាចបញ្ចប់វិវាទរបស់ពួកគេ។”

សមាសភាពនៃគណប្រតិភូ រួមមាន កញ្ញា យូ សួនទី អាជ្ញាកណ្តាលរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល, លោកស្រី ប៊ូ ច័ន្ទវាសនា ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល, លោកស្រី ស៊ូ សោភា នាយកផ្នែកច្បាប់នៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល, និងលោក វណ្ណដេត តារារដ្ឋ ជាមន្ត្រីទំនាក់ទំនង។

ស្ថាប័នការងារយុត្តិធម៌របស់ប្រទេសអូស្ត្រាលី (FWA) គឺជាអង្គជំនុំជម្រះផ្នែកទំនាក់ទំនងកន្លែងការងារជាតិរបស់ប្រទេសអូស្ត្រាលី។

អង្គជំនុំជម្រះនេះ គឺជាស្ថាប័នឯករាជ្យមួយដែលមានអំណាចផ្នែកច្បាប់ ក្នុងការបំពេញមុខងារផ្សេងៗជាច្រើន ទាក់ទងនឹងទំនាក់វិជ្ជាជីវៈ ដូចជាការផ្តល់សំណាញ់សុវត្ថិភាពសម្រាប់លក្ខខណ្ឌអប្បបរមា ការផ្តល់សំណងចំពោះករណីបណ្តេញចេញដោយខុសច្បាប់ ការគ្រប់គ្រងលើវិធានការឧស្សាហកម្ម និងការដោះស្រាយវិវាទការងាររួម និងវិវាទការងារបុគ្គល តាមរយៈការផ្សះផ្សា ការធ្វើសន្ទានកម្ម និងអាជ្ញាកណ្តាល។

# តំណាងនិយោជក និងសហជីពស្វែងយល់អំពីអនុស្សារណៈនៃការយោគយល់គ្នា នៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងដំណើរការមជ្ឈត្តកម្មការងារ

អនុស្សារណៈ នៃការយោគយល់គ្នានៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ដែលទាក់ទងនឹងការចងកាតព្វកិច្ចដោយអាជ្ញាកណ្តាលស្តីពីវិវាទអំពីសិទ្ធិនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានចុះហត្ថលេខាដោយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងសម្ព័ន្ធសហជីពទាំងប្រាំមួយនៅក្នុងខែកញ្ញា ឆ្នាំ២០១០។ តាមការអញ្ជើញរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល អ្នកគ្រប់គ្រង និងសហជីពនៅថ្នាក់សហគ្រាសដែលគ្របដណ្តប់ដោយអនុសារណៈនៃការយោគយល់គ្នានេះ រួមទាំងតំណាងមកពីស្ថាប័នការងារផ្សេងៗទៀតបានចូលរួមការប្រជុំនៅឯការិយាល័យរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងខែធ្នូ ឆ្នាំ២០១០។នៅ

តទៅទំព័រ ៥



កញ្ញា ជុំ ចរិយា មន្ត្រីច្បាប់ជាន់ខ្ពស់របស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ផ្តល់ព័ត៌មានពីអនុស្សារណៈក្នុងវិស័យកាត់ដេរសំលៀកបំពាក់ ដល់សហជីព និងអ្នកគ្រប់គ្រងនៅកម្រិតសហគ្រាស

## តំណាងនិយោជក...

*តមកពីទំព័រ ៤*

ក្នុងការប្រជុំនេះអ្នកចូលរួមបានយល់ដឹងអំពីអនុសារណៈ នៃការយោគយល់គ្នានេះ និងការអនុវត្តទាក់ទងអនុស្សារណៈនេះនៅថ្ងៃអនាគត និងផលប៉ះពាល់ដំណើរការអាជ្ញាកណ្តាលនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ទាក់ទងនឹងការចងកាតព្វកិច្ចដោយអាជ្ញាកណ្តាល អ្នកចូលរួមបានទទួលស្គាល់សារៈសំខាន់នៃការរៀបចំសំណុំរឿងអោយបានល្អ និងការបង្ហាញសំណុំរឿងនៅចំពោះក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ជាមួយនឹងអាជ្ញាកណ្តាលជាប់កាតព្វកិច្ចចុងក្រោយ ភាគីវិវាទត្រូវតែអនុវត្តការសំរេចចិត្តដែលជាប់កាតព្វកិច្ចភ្លាមៗ។ ខុសពីការសំរេចចិត្តមិនជាប់កាតព្វកិច្ច ចំពោះការសំរេចចិត្តជាប់កាតព្វកិច្ច ភាគីមិនអាចដាក់ពាក្យបណ្តឹងជំទាស់បានទេ។ ក្នុងន័យនេះ សហគ្រាសនិងបុគ្គលិកអាចបញ្ចប់វិវាទការងាររបស់ពួកគេ ហើយដូចនេះពួកគេអាចផ្តោតទៅលើសង្វាក់ការងារ និងការរកប្រាក់ចំណូល។

មុនពេលអាជ្ញាកណ្តាលជាប់កាតព្វកិច្ចចូលជាធរមាននៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០១១ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានរៀបចំវគ្គជម្រាបជូនដំណឹងចំនួនប្រាំវគ្គ ជូនដល់ភាគីដែលពាក់ព័ន្ធ។ វគ្គជម្រាបជូនដំណឹងលើកទីមួយត្រូវបានធ្វើឡើងនៅថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១០ដោយមានអ្នកចូលរួមចំនួន ១១ នាក់មកពីសមាគមន៍រោងចក្រកាត់ដេរកម្ពុជា ILO-រោងចក្រកាន់តែប្រសើរនៅកម្ពុជា ILO-គម្រោងដោះស្រាយវិវាទការងារ មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ (CLEC)សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) និងមណ្ឌលព័ត៌មានកម្មករ។

វគ្គជម្រាបជូនដំណឹងលើកទីពីរត្រូវបានធ្វើឡើងនៅថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១០ដោយមានអ្នកចូលរួមចំនួន ១៤ នាក់ មកពីសហព័ន្ធសហជីពធំៗចំនួនប្រាំមួយ ហត្ថលេខីលើអនុស្សារណៈនៃការយោគយល់គ្នា និងអង្គការសមាហរណ៍កម្មធនធានឆ្ពោះទៅគុណភាព។

វគ្គជម្រាបជូនដំណឹងលើកទីបី ទីបួន និងទីប្រាំ ត្រូវបានធ្វើឡើងនៅថ្ងៃទី២១, ២៣, និង ២៧ ខែធ្នូ ដោយមានអ្នកចូលរួមសរុបចំនួន ៥០ នាក់ មកពីសហជីព និងថ្នាក់គ្រប់គ្រងនៅកម្រិតសហគ្រាស ដែលធ្លាប់បាននាំសំណុំរឿងជាច្រើនមកកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅក្នុងការប្រជុំនេះ អ្នកបណ្តុះបណ្តាលរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថាអ្នកតំណាងរបស់អ្នកគ្រប់គ្រង និងសហជីពនៅថ្នាក់សហគ្រាសមិនបានដឹងអំពីអនុស្សារណៈ នៃការយោគយល់គ្នានេះទេ។

លោកស្រី អ៊ួង សុភាពប្រធានសហជីពនៅរោងចក្រកាត់ដេរ ភីភីស៊ីអេស បាននិយាយថាខ្ញុំមិនដឹងច្បាស់អំពីអនុស្សារណៈនៃការយោគយល់គ្នានេះទេ មុនខ្ញុំចូលរួមការប្រជុំផ្តល់ពត៌មាននេះនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

"ខ្ញុំត្រូវតែមានការប្រុងប្រយត្ន័បន្ថែមទៀតជាមួយការរៀបចំសំណុំរឿង ដោយសារតែការដោះស្រាយវិវាទ(វិវាទអំពីសិទ្ធិ) នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលឥលូវត្រូវជាប់កាតព្វកិច្ចចំពោះភាគីទាំងពីរ។"

នេះបង្ហាញពីតំរូវការរបស់សមាគមនិយោជក សម្ព័ន្ធសហជីព និងភ្នាក់ងារក្នុងវិស័យការងារដែលពាក់ពន្ធ័ ដើម្បីលើកកំពស់នៃការយល់ដឹង នៃអនុស្សារណៈ នៃការយោគយល់គ្នានេះក្នុងចំណោមនិយោជក និងសហជីព។ ការលើកកំពស់ការយល់ដឹងនេះមានសារៈសំខាន់ក្នុងការធានាថា ការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នានេះនឹងទទួលបានជោគជ័យ ហើយរួមចំណែកពង្រឹងស្ថេរភាពនៅក្នុងទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់។

# ការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នាក្នុងឧស្សាហកម្មកាត់ដេរ អាចបង្កើនប្រាក់ចំណេញ និងប្រាក់ឈ្នួល

នៅថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០១០ សមាគមរោងចក្រកាត់ដេរកម្ពុជា និងសហព័ន្ធសហជីព សម្ព័ន្ធសហព័ន្ធសហជីពធំៗចំនួនប្រាំមួយបានចុះហត្ថលេខាលើ អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការពង្រឹងទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ដែលបានចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០១១។ អនុស្សារណៈនេះ អាចជួយលើក កំពស់ផលិតភាព និងប្រាក់ចំណេញរបស់និយោជកព្រមទាំងប្រាក់ឈ្នួលរបស់និយោជិតនៅក្នុងឧស្សាហកម្មកាត់ដេរ តាមរយៈការជួយកសាងសហប្រតិបត្តិការណ៍ល្អ និងប្រកបដោយនិរន្តរភាពនៅកន្លែងធ្វើការងារ ដើម្បីកាត់បន្ថយការអូសបន្លាយនៃវិវាទការងារនិងដើម្បីកាត់បន្ថយករណីកូដកម្ម និងឡុកអៅ។ ចំណុចនេះ មានសារៈសំខាន់ជាពិសេសនៅក្នុងឧស្សាហកម្មកាត់ដេរ ដែលជាវិស័យអាចផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត ប្រមាណ ៣៥០.០០០ នាក់ នៅក្នុងប្រទេសកម្ពុជា និងជួយគាំទ្រជីវភាពរបស់សាច់ញាតិពួកគេជា ច្រើននាក់ទៀត។

លោក វង្ស សុវណ្ណ ប្រធានសហព័ន្ធសហជីពការងារកម្មករកម្ពុជា បានបញ្ជាក់ពីផលប្រយោជន៍នៃការជ្រើសរើសអាជ្ញាកណ្តាលជាប់កាតព្វកិច្ចដែលចែងនៅក្នុងអនុស្សារណៈ “នៅពេលចេញសេចក្តីបង្គាប់ ហើយភាគីទាំងពីរអនុវត្តពួកគេនឹងមានភាពសុដុមរមនាធ្វើការជាមួយគ្នា ក៏ដូចជាអាជីវកម្មទាំងមូលដំណើរការបានល្អ”។ គាត់បានបន្ថែមថាគាត់បានប្រជុំ និងធ្វើសកម្មភាពផ្សេងៗទៀតជាមួយសហជីព ដើម្បីអោយពួកគេយល់ដឹង និងគោរពតាមអនុស្សារណៈនេះ។

ក្រោមអនុស្សារណៈនៃការយោគយល់គ្នានេះ ភាគីទាំងអស់បានព្រមព្រៀងគ្នាលើគោលការណ៍ និងការប្តេជ្ញាចិត្តសំខាន់ៗមួយចំនួនដែលមានគោលដៅលើកកំពស់ ភាពសុខដុមនៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ ក្នុងឧស្សាហកម្មកាត់ដេរនៅប្រទេសកម្ពុជា។ ចំណុចមួយចំនួន នៅក្នុងអនុស្សារណៈនៃការយោគយល់គ្នានោះរួមមានការគោរពតាមច្បាប់ជាតិ ការគាំទ្រឲ្យមានអនុញ្ញារួម ការគាំទ្រចំពោះអនុសញ្ញារួម ការគាំទ្រឲ្យសហជីពដែលមានភាពជាតំណាងបំផុតធ្វើជាភ្នាក់ងារចរចារផ្តាច់មុខ តាងនាមឲ្យកម្មករនិយោជិតក្នុងសហគ្រាសទាំងមូល និងការដាក់វិវាទពាក់ព័ន្ធនឹងសិទ្ធិការងារដែលមានស្រាប់ មកដោះស្រាយតាមរយៈអាជ្ញាកណ្តាលចុងក្រោយ និងជាប់កាតព្វកិច្ច នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។អនុស្សារណៈនៃកាយោគយល់គ្នានេះក៏បានបញ្ជាក់ផងដែរថា ភាគីទាំងអស់បានព្រមព្រៀងគ្នាចាត់ទុកអនុស្សារណៈ និងបទបញ្ញត្តិនានានៅក្នុងអនុស្សារណៈនេះជាកញ្ចប់ទាំងមូលមួយ។

អ្វីដែលគួរឲ្យកត់សំគាល់ សម្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺកិច្ចព្រមព្រៀងរបស់ភាគីក្នុងការជ្រើសរើសយកការដោះស្រាយតាមរយៈអាជ្ញាកណ្តាលជាប់កាតព្វកិច្ច ទៅលើវិវាទអំពីសិទ្ធិការងារដែលមានស្រាប់ ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល និងត្រូវគោរពតាមនីតិវិធីដោះស្រាយវិវាទជាពិសេស គឺមិនត្រូវបែរទៅរកការធ្វើកូដកម្ម ឬឡុកអៅ ក្នុងអំឡុងពេលដំណើរការការដោះស្រាយវិវាទឡើយ។ សម្រាប់វិវាទទាំងអស់នេះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងក្លាយជាសេចក្តីសម្រេចចុងក្រោយ និងចងកាតព្វកិច្ចសម្រាប់ភាគីវិវាទដែលនេះមានន័យថា ភាគីត្រូវតែអនុវត្តសេចក្តីសម្រេចនោះភ្លាមៗ។ តាមរយៈការអនុវត្តសេចក្តីសម្រេចដោយសុឆន្ទៈភាគីនឹងអាចសន្សំពេលវេលាកម្លាំង និងធនធានបានយ៉ាងច្រើនជាហេតុធ្វើឲ្យពួកគេអាចចំណាយពេលវេលា កម្លាំង និងធនធានទាំងនោះ ដើម្បីសម្រេចបាននូវបេសកកម្មចំបងរបស់ពួកគេពោលគឺ៖ បង្កើនប្រាក់ចំណូល និងទទួលបានប្រាក់ឈ្នួល។

ដោយមានការរំពឹងទុកថា សេចក្តីបង្គាប់នឹងចងកាតព្វកិច្ចចំពោះភាគីទាំងអស់នេះជាពេលវេលាសំខាន់ ជាងពេលណាៗទាំងអស់ ដែលភាគីវិវាទត្រូវរៀបចំសំណុំរឿង របស់ខ្លួនឲ្យបានល្អនៅពេលត្រូវមកកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្តេជ្ញាចិត្តផ្តល់ការគាំទ្រចំពោះភាគីនៃអនុស្សារណៈនៃការយោគយល់គ្នានៅក្នុងការ

*តទៅទំព័រ ៦*

**ការអនុវត្ត...**

*តមកពីទំព័រ ៥*

អនុវត្តកិច្ចព្រមព្រៀងនេះ។ នៅឆ្នាំ ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបន្តផ្តល់ការបណ្តុះបណ្តាលដល់និយោជក និងសហជីពអំពីការត្រៀមសំណុំរឿង និងការបង្ហាញសំណុំរឿងប្រកបដោយប្រសិទ្ធភាព។ ជាងនេះទៅទៀត មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល មានផែនការរៀបចំការបណ្តុះបណ្តាល ដែលចំទៅតាមសេចក្តីត្រូវការរបស់ភាគីក្នុងអនុស្សារណៈនៃការយោគយល់គ្នានៅក្នុងវិស័យកាត់ដេរ ក្នុងឆ្នាំ ២០១១ ទាំងមូល។

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល សូមកោតសរសើរចំពោះថ្នាក់ដឹកនាំរបស់សមាគមរោងចក្រកាត់ដេរកម្ពុជា និងសហជីពការងារទាំងអស់ដែលបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាដ៏មានសារៈសំខាន់ និងដែលមានសក្តានុពលដ៏ធំធេងក្នុងការបង្កើនប្រាក់ចំណេញរបស់និយោជក និងប្រាក់ឈ្នួលរបស់កម្មករនិយោជិត ក៏ដូចជាជីវភាពរបស់ប្រជាជនកម្ពុជារាប់ពាន់នាក់។ ក្រោយមានអនុស្សារណៈ នៃការយោគយល់គ្នានេះ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងរងចាំមើលសមាគមន៍រោងចក្រកាត់ដេរកម្ពុជា និងសមាជិករបស់ខ្លួនក៏ដូចជាសហព័ន្ធសហជីព និងសម្ព័ន្ធសហព័ន្ធសហជីព និងស្ថាប័ន ដែលពាក់ព័ន្ធទាំងអស់ អនុវត្តអនុស្សារណៈនេះ ប្រកបដោយជោគជ័យក្នុងឆ្នាំ២០១១។ យើងសង្ឃឹមថា ឆ្នាំ២០១១ នឹងនាំមកនូវទំនាក់ទំនងវិជ្ជាជីវៈដ៏មានស្ថេរភាពក្នុងវិស័យកាត់ដេរ ក្រោមកិច្ចដឹកនាំដ៏រឹងមាំ។

លោក វ៉ាន ស៊ូអៀង ប្រធានសមាគមន៍នយោជកនៅកម្ពុជា បាននិយាយថា "យើងជឿជាក់ថាវា( ការបង្កើតអនុស្សារណៈក្នុងវិស័យកាត់ដេរសំលៀកបំពាក់ជាការត្រឹមត្រូវ ហើយយើងនឹងបង្ហាញសហជីពយើងប្រកាន់ភ្ជាប់ច្បាប់ និងចង់ធ្វើការជាដៃគូដ៏ស្មោះត្រង់ជាមួយសហជីពក្នុងគោលបំណងឲ្យទំនាក់ទំនងវិជ្ជាជីវៈល្អនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ ។

## លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រៀមទទួលចុះបញ្ជីសំណុំរឿងវិវាទការងារដែលគ្រប់ដណ្តប់ដោយអនុស្សារណៈនៃការយោគយល់គ្នាក្នុងវិស័យកាត់ដេរ

ខចែងស្តីពីអាជ្ញាកណ្តាលជាប់កាតព្វកិច្ចនៅក្នុងអនុស្សារណៈនៃការយោគយល់គ្នាក្នុងវិស័យកាត់ដេរ បានជះឥទ្ធិពលមកលើដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ ២០១០ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរផ្នែករដ្ឋបាល ចំពោះសំណុំរឿងវិវាទការងារ។

មានការផ្លាស់ប្តូរមួយចំនួន ទៅលើនីតិវិធីសវនាការដែលធ្លាប់មានពីមុនមក។ មន្ត្រីលេខាធិការដ្ឋាន នឹងពន្យល់ដល់ភាគី អំពីវិធាននានាក្នុងសវនាការ និងជម្រាបជូនដល់ភាគីអំពីប្រសិទ្ធភាពនៃអាជ្ញាកណ្តាលជាប់កាតព្វកិច្ច ទៅលើវិវាទអំពីសិទ្ធិ។ បន្ថែមលើនេះទៀត មន្ត្រីលេខាធិការដ្ឋាននឹងរៀបចំកិច្ចព្រមព្រៀងដាច់ដោយឡែកមួយទៀតសម្រាប់ឲ្យភាគីក្នុងអនុស្សារណៈនៃការយោគយល់គ្នា ដើម្បីចុះហត្ថលេខា បញ្ជាក់ថាពួកគេ គឺជាហត្ថលេខី នៅក្នុងអនុស្សារណៈនៃការយោគយល់គ្នា ហើយតាមរយៈលិខិតនេះ ពួកគេជ្រើសរើសយកអាជ្ញាកណ្តាលជាប់កាតព្វកិច្ច សម្រាប់វិវាទអំពីសិទ្ធិ។ ភាគីសូមរក្សាសិទ្ធិ ក្នុងការជ្រើសរើសអាជ្ញាកណ្តាលមិនជាប់កាតព្វកិច្ចសម្រាប់វិវាទអំពីប្រយោជន៍របស់ពួកគេ។ បន្ទាប់ពីក្រុមអាជ្ញាកណ្តាលចេញសេចក្តីសម្រេចលើសំណុំរឿងហើយ មន្ត្រីលេខាធិការដ្ឋាន នឹងបញ្ជូនសេចក្តីបង្គាប់ទៅឲ្យភាគី និងផ្ញើលិខិតទៅក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ ដោយបញ្ជាក់ថា វិវាទអំពីសិទ្ធិនឹងចូលជាធរមានភ្លាមៗ។

វិវាទអំពីសិទ្ធិទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តសិទ្ធិដែលមានស្រាប់ណាមួយ ដែលមានចែងនៅក្នុងច្បាប់ កិច្ចសន្យា អនុសញ្ញារួម ឬការអនុវត្តកន្លងមក។ វិវាទអំពីប្រយោជន៍ទាក់ទងនឹងអត្ថប្រយោជន៍នាពេលអនាគត ដែលមិនផ្អែកលើសិទ្ធិ ដែលមានស្រាប់ណាមួយ ដែលមានចែងនៅក្នុងច្បាប់ ឬការអនុវត្តបច្ចុប្បន្នឡើយ។សម្រាប់ព័ត៌មានបន្ថែម ស្តីពីភាពខុសគ្នារវាងវិវាទអំពីសិទ្ធិ និងវិវាទអំពីប្រយោជន៍ នឹងមានផ្តល់ជូនតាមរយៈវគ្គបណ្តុះបណ្តាល និងឯកសារបោះពុម្ពផ្សាយនៅមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ផ្ទះលេខ ៧២ ផ្លូវលេខ៥៩២ (កែងផ្លូវ ៣២៧) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ : +៨៥៥ (០២៣) ៨៨១ ៨១៤
ទូរសារ : +៨៥៥ (០២៣) ៨៨១ ៩១៨
សារអេឡិចត្រូនិច : info@arbitrationcouncil.org វិបសាយ : www.arbitrationcouncil.org

ប្រសិនបើមានព័ត៌មានដែលលោកអ្នកចង់ផ្សព្វផ្សាយក្នុងព្រឹត្តិបត្រក្រុមប្រឹក្សាអាជ្ញាកណ្តាល សូទំនាក់ទំនង :
**លោក វណ្ណដេត តារារដ្ឋ**
មន្ត្រីទំនាក់ទំនង
ទូរសព្ទលេខ : +៨៥៥ (០១២) ៩១០ ៩៩០
សារអេឡិចត្រូនិច : dvandeth@arbitrationcouncil.org